ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**
**អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន**

លេខ: ៤០៣៦ អ.រ.ម

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២

**សូមគោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប.**

**តាមរយៈ:** **ឯកឧត្តមរដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋានគ.ជ.អ.ប**

ខុទ្ទកាល័យឯកឧត្តម ស ខេង
ចុះបញ្ជីលេខចូល
លេខ: 958
ថ្ងៃ 06.11.12
ម៉ោង: ... ល្ងាច ...

**កម្មវត្ថុ** ៖ សំណើសុំគោលការណ៍រៀបចំទម្រង់នៃការិយាល័យច្រកចេញចូលតែមួយនៅ**ស្រុកបវេល នៃខេត្តបាត់ដំបង ក្រុងសិរីសោភ័ណនៃខេត្តបន្ទាយមានជ័យ ក្រុងកំពង់ចាមនៃខេត្តកំពង់ចាម ក្រុងព្រៃវែងនៃខេត្តព្រៃវែង និងក្រុងស្វាយរៀងនៃខេត្តស្វាយរៀង**។

**យោង** ៖- សេចក្តីសម្រេចលេខ ១០២៨សសរ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃ ស្តីពីការកំណត់ក្រុង ស្រុក ខណ្ឌគោលដៅ នៃគម្រោងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ សម្រាប់អនុវត្តក្នុងឆ្នាំ ២០១២-២០១៣

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្នុងគោលបំណងដើម្បីបង្កើនប្រសិទ្ធភាព និងការបង្កិតការផ្តល់សេវាសាធារណៈទៅកៀកជិតជាមួយប្រជាពលរដ្ឋតាមរយៈការិយាល័យច្រកចេញចូលតែមួយ អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន បានរៀបចំឲ្យមានការសិក្សាអំពីជម្រើសនៃការបង្កើតការិយាល័យនេះនៅស្រុកជនបទមួយចំនួន។ លទ្ធផលនៃការសិក្សានេះ ត្រូវបានយកមកបង្ហាញ និងពិគ្រោះយោបល់ក្នុងក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួងកាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ដើម្បីកំណត់ជ្រើសរើសស្រុកជនបទមួយ និងទម្រង់នៃការបង្កើតការិយាល័យច្រកចេញចូលតែមួយនៅស្រុកជនបទនោះ។ នៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់បច្ចេកទេសអន្តរក្រសួង និងអ្នកពាក់ព័ន្ធនានា បានឯកភាពតាមរបាយការណ៍នៃការសិក្សានេះ ដោយបានសម្រេចជ្រើសរើសយក**ស្រុកបវេលនៃខេត្តបាត់ដំបង** ធ្វើជាស្រុកជនបទគោលដៅមួយ សម្រាប់បង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ។ ព្រមជាមួយនេះ អង្គប្រជុំក៏បានឯកភាពលើទម្រង់នៃការបង្កើតការិយាល័យច្រកចេញចូលតែមួយនៅស្រុកជនបទនេះ ដោយបង្កើតឲ្យមានផ្នែកជួរមុខបន្ថែមនៅតាមបណ្តាឃុំចំនួនបី និងបង្កើតឲ្យមានផ្នែកជួរមុខចល័តសម្រាប់ឃុំមួយចំនួនទៀត អាស្រ័យទៅតាមស្ថានភាពជាក់ស្តែង។ ដោយអនុវត្តតាមស្មារតីនៃកិច្ចប្រជុំនេះ ក្រុមគាំទ្រថ្នាក់ក្រុង ស្រុក ខណ្ឌ នៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក៏បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំខេត្ត ស្រុក និងគ្រប់ឃុំទាំងអស់នៃស្រុកបវេល ដើម្បីជ្រើសរើសទីតាំងឃុំដែលមានលក្ខណៈសមស្របសម្រាប់រៀបចំឲ្យមានផ្នែកជួរមុខ និងជួរមុខចល័ត នៅក្នុងស្រុកបវេលនៃខេត្តបាត់ដំបង។

ទន្ទឹមនឹងនោះ អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក៏បានរៀបចំឲ្យមានក្រុមការងារមួយដើម្បីធ្វើការសិក្សា វាយតម្លៃលើក្រុងគោលដៅថ្មីចំនួន៤ ផ្សេងទៀត ដែលរួមមាន **ក្រុងព្រៃវែងនៃខេត្តព្រៃវែង ក្រុងកំពង់ចាមនៃខេត្តកំពង់ចាម ក្រុងស្វាយរៀងនៃខេត្តស្វាយរៀង និងក្រុងសិរីសោភ័ណនៃខេត្តបន្ទាយមានជ័យ** ដើម្បីកំណត់អំពីទម្រង់នៃការបង្កើតការិយាល័យច្រកចេញចូលតែមួយ ឲ្យបានសមស្របផងដែរ។ ការចុះសិក្សាវាយតម្លៃនេះ ក្រុមការងារបានជួបប្រជុំពិភាក្សា និងពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំខេត្ត មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ ថ្នាក់ដឹកនាំក្រុង មន្ត្រីពាក់ព័ន្ធជុំវិញក្រុង ព្រមទាំងតំណាងក្រុមប្រឹក្សាសង្កាត់ផងដែរ។ ជាមួយគ្នានេះ ក្រុមការងារក៏បានចុះពិនិត្យជាក់ស្តែងលើទីតាំង និងបរិវេណរបស់សាលាក្រុង និងសង្កាត់មួយចំនួន ដើម្បីពិនិត្យមើលពីលទ្ធភាពនៃការរៀបចំការិយាល័យនេះ ។

ផ្អែកលើលទ្ធផលនៃការសិក្សាទាំងពីរនេះ **ខ្ញុំសូមគោរពស្នើសុំគោលការណ៍ដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដូចខាងក្រោម៖

១-រៀបចំទម្រង់ការិយាល័យច្រកចេញចូលតែមួយពេញលេញ ដោយមានផ្នែកជួរមុខ និងផ្នែកជួរក្រោយ នៅក្នុងបរិវេណសាលាស្រុកបវេលនៃខេត្តបាត់ដំបង សាលាក្រុងសិរីសោភ័ណនៃខេត្តបន្ទាយមានជ័យ សាលាក្រុងកំពង់ចាមនៃខេត្តកំពង់ចាម សាលាក្រុងព្រៃវែងនៃខេត្តព្រៃវែង និងសាលាក្រុងស្វាយរៀងនៃខេត្តស្វាយរៀង។

២-រៀបចំឲ្យមានផ្នែកជួរមុខបន្ថែម នៅសាលាឃុំចំនួនបីនៃស្រុកបវេលនៃខេត្តបាត់ដំបង គឺ**ឃុំល្វា ឃុំក្តុលតាហែន និងឃុំខ្នាចរមាស**។ ជាមួយគ្នានេះផងដែរ ស្នើសុំរៀបចំឲ្យមានផ្នែកជួរមុខចល័តនៅតាមបណ្តាឃុំមួយចំនួនទៀត រួមមាន **ឃុំព្រៃខ្ពស់ ឃុំអំពិលប្រាំដើម ឃុំបឹងប្រាំ និងឃុំឃ្លាំងមាស ឬតាមបណ្តាឃុំ ភូមិដទៃទៀត** តាមការចាំបាច់។

៣-រៀបចំឲ្យមានផ្នែកជួរមុខបន្ថែមនៅសាលាសង្កាត់ចំនួនមួយ នៃក្រុងសិរីសោភ័ណ នៃខេត្តបន្ទាយមានជ័យ គឺ**សង្កាត់ភ្នៀត** និងរៀបចំឲ្យផ្នែកជួរមុខចល័តនៅតាមបណ្តាសង្កាត់ ឬតាមបណ្តាភូមិដទៃទៀតតាមការចាំបាច់។

៤-រៀបចំឲ្យមាននីតិវិធី និងរបៀបរបបធ្វើការងារមួយដោយឡែក សម្រាប់ការគ្រប់គ្រងការចាត់ចែងការងារ ការទទួលខុសត្រូវ តួនាទី ភារកិច្ច និងទំនាក់ទំនងការងារ រវាងផ្នែកជួរមុខនៅតាមឃុំ សង្កាត់ ព្រមទាំងផ្នែកជួរមុខចល័ត ជាមួយនឹងផ្នែកជួរក្រោយនៅសាលាក្រុង ស្រុក។

អាស្រ័យហេតុនេះ សូម**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាពិនិត្យ សម្រេចដ៏ខ្ពង់ខ្ពស់។

សូម**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគោរវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

01-11-2012

**អគ្គនាយក**

**លេខ_ទី**

**សក់ សេដ្ឋៈ**